# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 1248

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការសាងសង់ និងកែលម្អមណ្ឌលស្ដារនីតិសម្បទាជនរងគ្រោះ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |

៣. ចំណាយគម្រោងសរុប $2,247,717

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

| | |
|---|---|
| RESPONSIBLE UNIT | Department of Victims Protection |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានគាំពារជនរងគ្រោះ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

បញ្ចកោណទី១- ការអភិវឌ្ឍមូលធនមនុស្ស

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ប្រជាជនដែលរស់នៅទីជនបទភាគច្រើនបានចាកចេញពីស្រុកកំណើតមករកការងារធ្វើការនៅទីក្រុង និងតំបន់អភិវឌ្ឍន៍មួយចំនួនដែលនៅក្នុងប្រទេស និងមួយចំនួនទៀតចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ដើម្បីរកប្រាក់កម្រៃបង្កើនជីវភាពគ្រួសារឱ្យបានធូរធារជាងមុន។ ដូច្នេះហើយទើបមានជនខិលខូចមួយចំនួនបានប្រើប្រាស់នូវឱកាសនេះក្នុងការបោកបញ្ឆោតប្រជាជនមួយភាគតូចដើម្បីកេងយកផលប្រយោជន៍តាមរយៈការរកការងារឱ្យធ្វើ ដែលជាហេតុបណ្ដាលឱ្យមានអ្នកធ្លាក់ខ្លួនរងគ្រោះដោយការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ និងអាជីវកម្មផ្លូវភេទជាដើម ដែលនេះជាបញ្ហាគួរឱ្យព្រួយបារម្ភ និងយកចិត្តទុកដាក់។ ដើម្បីទទួល និងជួយជនរងគ្រោះទាំងនោះ ក្រសួងចាំបាច់ត្រូវបង្កើតមជ្ឈមណ្ឌលនេះឡើងសម្រាប់ផ្ដល់ការស្នាក់នៅសុវត្ថិភាព ថែទាំ ស្ដារនីតិសម្បទា អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មុនពេលធ្វើសមាហរណកម្មត្រឡប់ទៅគ្រួសារ ឬសហគមន៍វិញក្នុងគោលបំណងកាត់បន្ថយចំនួនជនរងគ្រោះ និងបញ្ចៀសពួកគាត់ពីការរងគ្រោះជាថ្មីម្ដងទៀត។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

**១១. វិស័យ** ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

**សហគមន៍ និងសេវាកម្មសង្គម**

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

**កណ្ដាល,**

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

**ទទួល ស្តារនីតិសម្បទា ( ទាំងផ្លូវកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍ ) និងផ្តល់ការអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ធ្វើអាជីវកម្មផ្លូវភេទ កេងប្រវ័ញ្ច និងទម្រង់ផ្សេងទៀត នៃការរំលោភបំពាន ដើម្បីជួយឱ្យពួកគាត់អាចរស់នៅប្រកបដោយជីវភាពថ្លៃថ្នូរនៅក្នុងគ្រួសារ និងសហគមន៍ក្រោយធ្វើសមាហរណកម្ម ពិសេសធានាថាពួកគាត់នឹងមិនត្រឡប់មករងគ្រោះសារជាថ្មី។**

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

ទី១០: ការសាងសង់
- សាងសង់ក្លោងទ្វារ = ៦៥.៣៦០ ដុល្លារអាមេរិក
- សាងសង់របងឥដ្ឋ និងបំពាក់បន្លាលួស = ៩១.៥០៤ ដុល្លារអាមេរិក
- ប៉ុស្តិ៍យាម = ៩.១៩១,២៥ ដុល្លារអាមេរិក
- ផ្លូវបេតុង = ៤៧.៣៨៦ ដុល្លារអាមេរិក
- អគារស្នាក់នៅមន្ត្រី បុរស ស្ត្រី (២ជាន់ ១ខ្នង) = ៣១៣.៧២៨ ដុល្លារអាមេរិក
- អគាររដ្ឋបាល (២ជាន់ ១ខ្នង) = ១៩៦.០៨០ ដុល្លារអាមេរិក
- អគារអាហារដ្ឋាន ១ខ្នង = ៤៥.០៣៧,១២៥ ដុល្លារអាមេរិក
- ឃ្លាំងដាក់សម្ភារ ១ខ្នង = ៤៦.៩១៣,៦៧២ ដុល្លារអាមេរិក
- អគារសាលប្រជុំ ១ខ្នង = ១៣២.៣៥៤ ដុល្លារអាមេរិក
- អគារស្នាក់នៅជនរងគ្រោះបុរស ១ខ្នង = ១៥៤.៤១៣ ដុល្លារអាមេរិក
- អគារបណ្តុះបណ្តាលជនរងគ្រោះស្ត្រី ១ខ្នង = ១៤៧.០៦០ ដុល្លារអាមេរិក
- អគារស្នាក់នៅជនរងគ្រោះស្ត្រី ១ខ្នង = ១៥៤.៤១៣ ដុល្លារអាមេរិក

ទី២០: ការកែលម្អរ
- របងខាងមុខមណ្ឌលប្រវែង ៧២ ម៉ែត្រ = ១១.០២៩,៥ ដុល្លារអាមេរិក
- អគារបណ្តុះបណ្តាលជនរងគ្រោះបុរស ១ខ្នង = ២៧៩.៤១៤ ដុល្លារអាមេរិក
- ផ្លូវដើរឆ្លងកាត់ប្រក់ដំបូល ១ខ្នង = ២៧.៩៤១,៤ ដុល្លារអាមេរិក
- អគារផ្ទះបាយ ១ខ្នង = ២៦.១៤៤ ដុល្លារអាមេរិក
- អគារអាហារដ្ឋាន ១ខ្នង = ៣២.៦៨០ ដុល្លារអាមេរិក

ទី៣០: ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ
- លូឆ្លងកាត់ផ្លូវ = ៨១៧ ដុល្លារអាមេរិក
- ចាក់បេតុងចំណតរថយន្ត = ១២០.៦៦០,៦៨ ដុល្លារអាមេរិក
- រៀបការ៉ូឡា និងសួនច្បារមុខទីធ្លាអគារបណ្តុះបណ្តាល = ៤៣.៤០៣,១៣ ដុល្លារអាមេរិក
- សួនច្បារ និងដងទង់ជាតិ = ១៥.៣១៨,៧៥ ដុល្លារអាមេរិក
- ប្រព័ន្ធលូរំដោះទឹកភ្លៀង និងទឹកកខ្វក់ = ៥៦.៣៧៣ ដុល្លារអាមេរិក
- ចាក់ដីបំពេញទីធ្លាក្នុងមណ្ឌល = ៤៧.១៥៦,២១៨ ដុល្លារអាមេរិក
- ឈូសឆាយសម្អាតព្រៃក្នុងមណ្ឌល និងដឹកចេញ = ២០.៩៦០,១៣៥ ដុល្លារអាមេរិក
- ភ្ជាប់បណ្តាញអគ្គិសនី ទ្រីហ្វារ ៣៦អំពែ = ១២.៧៦៥,៥៥ ដុល្លារអាមេរិក
- ភ្ជាប់បណ្តាញទឹកស្អាត = ៦៧.៤០២,៥ ដុល្លារអាមេរិក
- រៀបចំប្រព័ន្ធអគ្គិសនីបំភ្លឺក្នុងមណ្ឌល = ១៨.៨៩៣,០៩ ដុល្លារអាមេរិក
- រៀបចំប្រព័ន្ធកាម៉េរាសុវត្ថិភាព = ៦៣.៣១៨ ដុល្លារអាមេរិក

ទឹកប្រាក់គម្រោងសរុប = ២.២៤៧.៧១៧ ដុល្លារអាមេរិក

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ដោយយោងអនុក្រឹត្យលេខ ៩៤ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានចង្អុលបង្ហាញឱ្យមានការរៀបចំសាងសង់មជ្ឈមណ្ឌលស្តារនីតសម្បទា និងបណ្តុះបណ្តាលជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលបច្ចុប្បន្នក្រសួងនៅមិនទាន់មាននៅឡើយ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ជនរងគ្រោះ និងងាយរងគ្រោះដែលកំពុងស្នាក់នៅក្នុងមណ្ឌលទទួលបានការថែទាំ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចូលរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចគ្រួសារឱ្យកាន់តែប្រសើរឡើង។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះមិនត្រឹមតែជួយផ្តល់ការស្នាក់នៅ និងថែទាំជនរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ពួកគាត់ថែមទៀតដើម្បីងាយស្រួលក្នុងការរកការងារធ្វើ និងប្រកបរបរចិញ្ចឹមជីវិត ក្រោយពេលធ្វើសមាហរណកម្មត្រឡប់ទៅគ្រួសារវិញដែលចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាផងដែរ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមានផលប៉ះពាល់តិចតួចដល់តួនាទីរបស់បុរស និងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះ ដោយសារតែជនរងគ្រោះដោយអំពើជួញដូរមនុស្សភាគច្រើនជាស្ត្រី ដូច្នេះ ស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះ ពិសេសការផ្តល់សេវា។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានទាំងជំនាញ និងបទពិសោធន៍។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**មិនមាន**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

មិនមាន

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្នើ | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 1,403.4 | 377.2 | 467.1 | 2,247.7 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 1,403.4 | 377.2 | 467.1 | 2,247.7 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,403.4 | 377.2 | 467.1 | 2,247.7 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 1,403.4 | 377.2 | 467.1 | 2,247.7 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: